**ប្រការ ២** : វិទ្យាល័យ ស្មោង ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិកផ្សេងៗទៀតមួយចំនួន តាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក_នាយករង នៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់ នាយក នាយករង នៃវិទ្យាល័យ ។

**ប្រការ ៤**: បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ នាយកវិទ្យាល័យស្មោង មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

**ហត្ថលេខា និង ត្រា**

**តូល ឡោះ**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ២៨៤ អយក.ប្រក**

**ប្រកាស**

**ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា ទឹកឃ្លាំង**

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញក្រឹត្យ_ច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់នាយកសាលាបឋមសិក្សាទឹកឃ្លាំងលេខ ១៨ បទឃ. ចុះថ្ងៃទី ២០_ ១២_១៩៩៥ និងលិខិតរបស់ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី ២ លេខ ៥៧ ខន២/៩៥ ចុះថ្ងៃទី ៥ កក្កដា ១៩៩៥ ។
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅនិង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកណ្ដាលប្ដូរឈ្មោះ សាលាបឋមសិក្សា ទឹកឃ្លាំង នៅឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល មកជា "សាលាបឋមសិក្សា **ហ៊ុន សែន** ទឹកឃ្លាំង" វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥_៩៦ នេះតទៅ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** មន្ទីរក្រសួងអប់រំ យុវជននិងកីឡា នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការនិងហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំ យុវជននិងកីឡាខេត្ត កណ្ដាល ការិយាល័យ អប់រំ យុវជន និង កីឡាស្រុកល្វាឯម នាយកសាលាបឋម សិក្សា **ហ៊ុន សែន** ទឹកឃ្លាំង មាន ភារកិច្ចអនុវត្តប្រកាសនេះ ។

**រដ្ឋលេខាធិការ**

**ហត្ថលេខា និង ត្រា**

**គា សាហាន**

* * *